ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង

**ស្តីពីការបន្តព្យួរកិច្ចសន្យាការងាររវាងតំណាងកម្មករនិយោជិត និងក្រុមហ៊ុន ម៉េម័រអង្គរ (ខេមបូឌា),**

សាខា សណ្ឋាគារម៉េម័រសៀមរាប កាលពីថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង ០៩ និង ៣០នាទី មាន ការប្រជុំស្តីពីការព្យួរកិច្ចសន្យាការងារ នៅក្រុមហ៊ុន ម៉េម័រអង្គរ (ខេមបូឌា), សាខា សណ្ឋាគារម៉េម័រសៀមរាប មានអាស័យដ្ឋានស្ថិតនៅ ភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។

## សមាសភាពចូលរួមក្នុងអង្គប្រជុំមានៈ

| **ក. តំណាងភាគីនិយោជក** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
|---|---|---|
| លោក បូរ សំប៊ុន | នាយកគ្រប់គ្រងទូទៅ | ០៦៩ ៨៩០ ៧៧៧ |
| អ្នកស្រី អ៊ុង សុគន្ធារី | ប្រធានផ្នែកធនធានមនុស្ស | ០៦៩ ៤១០ ៧៧៧ |

| **ខ. តំណាងភាគីកម្មករនិយោជិត** | **តួនាទី** | **លេខទូរស័ព្ទទំនាក់ទំនង** |
|---|---|---|
| លោក ឆេង ឆង | ប្រតិភូបុគ្គលិកពេញសិទ្ធិ | ០៦៩ ៤៧៥ ៧៧៧ |
| អ្នកស្រី បុង ពិសី | ប្រតិភូបុគ្គលិកជំនួយ | ០៦៩ ៤៦៤ ៧៧៧ |

ឆ្លងតាមការពិភាក្សាពន្យល់នូវគោលបំណងដែលពាក់ព័ន្ធទៅនឹង ការព្យួរកិច្ចសន្យាការងារឲ្យបាន សមស្របតាម សេចក្តីណែនាំលេខ ០៤៥/២០កប/ស.ណ.ន.ខ.ល ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០ របស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ភាគីទាំងពីរបានឯកភាពយល់ព្រមបន្តព្យួរកិច្ចសន្យាការងារចំពោះ កម្មករនិយោជិតចំនួន៥៩នាក់ក្នុងរយៈពេល ០២ខែ ដោយគិតចាប់ពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ថ្ងៃទី ១១ ខែមេសា ឆ្នាំ២០២១ ដោយទទួលបាននូវប្រាក់ឧបត្ថមពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗ ចំនួន ៤០ដុល្លា អា-មេរិក ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារនេះ។ សំរាប់ក្រុមហ៊ុន មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការ ផ្តល់ប្រាក់ឧបត្ថមបន្ថែមទៅដល់កម្មករនិយោជិតក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះឡើយ ដោយសារតែ ក្រុមហ៊ុនបានទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីជំងឺ COVID-19 ធ្វើឲ្យបាត់បង់ប្រាក់ចំណូលហើយបង្ខំចិត្តផ្អាក អាជីវកម្មមួយរយៈ។

ការពិភាក្សានេះត្រូវបានបញ្ចប់នៅវេលាម៉ោង ១៣ និង ៣០នាទី រសៀល ថ្ងៃ ខែ ឆ្នាំដដែល ដោយ មានការចុះហត្ថលេខា ព្រមព្រៀងរបស់តំណាងទាំងអស់ដែលអាចយកជាការបានចំពោះមុខច្បាប់។

កិច្ចព្រមព្រៀងខាងលើបង្ហាញពីព័ត៌មានពិត និងត្រឹមត្រូវរវាងភាគីដែលបានចុះហត្ថលេខាដូចខាង ក្រោមៈ

ហត្ថលេខា/ស្នាមមេដៃ

លោក បូរ សំប៊ុន
នាយកគ្រប់គ្រងទូទៅ

ហត្ថលេខា/ស្នាមមេដៃ

លោក ឆេង ឆង
ប្រតិភូបុគ្គលិកពេញសិទ្ធិ

អ្នកស្រី អ៊ឹង សុគន្ធារី
ប្រធានផ្នែកធនធានមនុស្ស

អ្នកស្រី បុង ពិសី
ប្រតិភូបុគ្គលិកជំនួយ